# សេចក្ដីជូនដំណឹងទាក់ទងនឹងសេវាកម្មបកប្រែផ្ទាល់មាត់សំរាប់ជនបរទេស

- ប្រសិនបើភាសាកំណើតរបស់អ្នកមិនមែនជាភាសាកូរ៉េ ហើយអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ផ្នែកច្បាប់ក្នុងការកាត់ក្ដីរបស់អ្នក ខាងតុលាការអាចជ្រើសរើសអ្នកបកប្រែផ្ទាល់មាត់ទៅតាមសំណើរបស់អ្នក ហើយអាចនឹងចាត់តាំងអ្នកបកប្រែផ្ទាល់មាត់សំរាប់អ្នក ទោះបីជាអ្នកមិនបានធ្វើការស្នើសុំក៏ដោយ។ ការបង់ថ្លៃបកប្រែ គឺជាបន្ទុករបស់អ្នក។

- ក៏ប៉ុន្តែ អ្នកអាចនាំអ្នកជួយបកប្រែមកជាមួយ ហើយប្រសិនបើមិនមានករណីអ្វីពិសេសនោះទេ អ្នកជួយបកប្រែរបស់អ្នក អាចនឹងត្រូវបានចាត់តាំងជាអ្នកជំនួយការបកប្រែផ្ទាល់មាត់ក្នុងពេលធ្វើការកាត់ក្ដី។ ប្រសិនបើអ្នកមានអ្នកជួយបកប្រែមកជាមួយ នោះអ្នកមិនចាំបាច់បង់ថ្លៃសេវាកម្មបកប្រែទេ។ អ្នកជំនួយការបកប្រែ ត្រូវភ្ជាប់មកនូវអត្តសញ្ញាណប័ណ្ណរបស់ខ្លួន។

- ប្រសិនបើអ្នកមិនមានអ្នកជួយបកប្រែ ហើយអ្នកមិនមានលទ្ធភាពក្នុងការបង់ថ្លៃបកប្រែផ្ទាល់មាត់ទេ ខាងតុលាការនឹងធ្វើសំណើជំនួយផ្នែកច្បាប់ (រដ្ឋាភិបាលផ្តល់ជំនួយសំរាប់ការចំណាយក្នុងការកាត់ក្តី) ដោយយោងទៅតាមសំណើរបស់អ្នក រឺរបស់អាជ្ញាធរ។ ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់អោយក្នុងលក្ខខណ្ឌមួយចំនួន លើថ្លៃតែម ថ្លៃបញ្ជូនឯកសារ និងការចំណាយក្នុងការកាត់ក្តីផ្សេងៗទៀត ដូចជាថ្លៃមេធាវីជាដើម។

- ជាព័ត៌មានបន្ថែម មានអ្នកបកប្រែស្ម័គ្រចិត្ត (ជាភាសាអង់គ្លេស ចិន និងជប៉ុន) នៅក្នុងតុលាការគ្រួសារសេអ៊ូល។ ប្រសិនបើអ្នកមានចំងល់ទាក់ទងនឹងនីតិវិធីនៃការកាត់ក្តី អ្នកអាចសាកសួរអ្នកបកប្រែស្ម័គ្រចិត្តសំរាប់ព័ត៌មានបន្ថែម (អ្នកបកប្រែទាំងអស់មិនមែន

ជាអ្នកបកប្រែផ្នែកច្បាប់ទេ
ប៉ុន្តែជាអ្នកបកប្រែស្ម័គ្រចិត្តដែលផ្តល់ព័ត៌មានទាក់ទងនឹងនីតិវិធីនៃការកាត់ក្តី)

[ព័ត៌មានបន្ថែម[☎ 02-530-2568]:, អ្នកបកប្រែស្ម័គ្រចិត្តៈ [☎ 02-530-2568]

- កំរងសំនួរខាងក្រោម ត្រូវបានរៀបចំឡើងដើម្បីសំរួលអោយមាននីតិវិធីនៃការកាត់ក្តីដោយរលូន ដោយការពារមិនអោយជនបរទេសដែលមានកំរិតភាសាកូរ៉េទាប ចូលរួមក្នុងការកាត់ក្តី ដោយមិនមានអ្នកបកប្រែ រឺជំនួយការក្នុងការបកប្រែឡើយ។

ដាក់ពាក្យខាងក្រោម មុននឹងដល់ការកាត់ក្តី។
(ប្រសិនបើអ្នកមានកំរិតភាសាកូរ៉េល្អគ្រប់គ្រាន់ រឺមានជំនួយការបកប្រែ នោះអ្នកមិនចាំបាច់ដាក់ពាក្យនេះទេ។)

ករណីលេខ. :　　　　　　　　　　ឈ្មោះ:

| | |
|---|---|
| តើភាសាមួយណា/ភាសាណាខ្លះដែលអ្នកប្រើប្រាស់? | □ រុស្ស៊ី □ ម៉ុងហ្គោលី □ វៀតណាម □ អង់គ្លេស<br>□ ជប៉ុន □ ចិន □ ថៃ □ ផ្សេងៗ<br>(　　　　　　) |
| តើអ្នកអាចប្រើប្រាស់ភាសាកូរ៉េដល់កំរិតណាដែរ? | □ អាចធ្វើការទំនាក់ទំនងដោយខ្លួនឯងបាន<br>□ មិនអាចធ្វើការទំនាក់ទំនងបាន ប្រសិនបើមិនមានអ្នកបកប្រែ។ |
| តើអ្នកនឹងនាំជំនួយការបកប្រែមកជាមួយដើម្បីជួយបកប្រែរឺទេ? | □ មាន □ មិនមាន<br>(លេខទូរស័ព្ទរបស់អ្នកមកជួយបកប្រែៈ　　)<br>(ទំនាក់ទំនងជាមួយអ្នកមកជួយបកប្រែៈ　　) |
| **ឆ្លើយនឹងសំនួរខាងក្រោម "ក្នុងករណីដែលអ្នកមិនមានអ្នកជួយបកប្រែមកជាមួយ"** | |
| តើអ្នកត្រូវការអ្នកបកប្រែផ្នែកច្បាប់រឺទេ? | □ ត្រូវការ　□ មិនត្រូវការ |

| | |
|---|---|
| តើអ្នកត្រូវការធ្វើការស្នើសុំជំនួយផ្នែកហិរញ្ញវត្ថុសំរាប់ការចំណាយលើការបកប្រែផ្នែកច្បាប់រឺទេ? | □ ត្រូវការ □ មិនត្រូវការ |